ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១៣៦/០៨ — ស៊ូតើថឹច**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ស៊ូតើថឹច និលធីងី**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៧៩ ៧៧២ ឬ ០១២ ៨៩៤ ៣០០ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក ស សំណាង | មេធាវីប្រចាំក្រុមហ៊ុន |
| ២- លោក លីវ ម៉ាន់ | ប្រធានរដ្ឋបាលក្រុមហ៊ុន |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ : **សហព័ន្ធសហជីព-សហជីពឃុំវជនខ្មែរ ប្រចាំរោងចក្រ ស៊ូតើថឹច**

អាសយដ្ឋាន : ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៣១០ ៣២០ ឬ ០៩២ ៨៩០ ១៤៨ ទូរសារ : គ្មាន

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត :

១- លោក លី គឹមអាន — មន្ត្រីសម្របសម្រួល សហព័ន្ធសហជីពយុវជនខ្មែរ

២- លោក ទិត្យ វណ្ណៈ — មន្ត្រីសម្របសម្រួល សហព័ន្ធសហជីពយុវជនខ្មែរ

៣- លោកស្រី យឹម បុប្ផា — ប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន ស៊ូភើចិច

៤- លោកស្រី សួន បុប្ផា — អនុប្រធានសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន ស៊ូភើចិច

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន សងប្រាក់ថ្លៃពិនិត្យកាយសម្បទា (សំបុត្រពេទ្យ) កន្លងមកជូនកម្មករនិយោជិតទាំងអស់វិញតាមតម្លៃជាក់ស្តែង ដែលកម្មករបានចំណាយ និងពេលដែលកម្មករទៅពិនិត្យសុខភាពជាកាលិក ការចេញសោហ៊ុយជាបន្ទុករបស់ក្រុមហ៊ុន ដោយហេតុថា ត្រង់នេះមានចែងក្នុងច្បាប់ស្តីពីការងារត្រង់មាត្រា២៤៧ ចំណុចទី៤ នៃកឋាខណ្ឌទី៣ (ចំណុច គ) ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានឡើយ ដោយហេតុថា ការពិនិត្យសុខភាពដំបូងរបស់កម្មករវាជាលក្ខខណ្ឌ ដើម្បីបំពេញមុននឹងយកកម្មករឱ្យចូលធ្វើការ ពោលគឺលិខិតប្រកាសធានាលើសុខភាពរបស់កម្មករម្នាក់ៗ ដែលត្រូវប្រកាសជូនក្រុមហ៊ុនគ្រាដំបូង។ ក្នុងករណីដែលក្រុមហ៊ុនត្រូវបញ្ជូនកម្មករទៅពិនិត្យសុខភាព ជាកាលិកក្រុមហ៊ុននឹងចេញថ្លៃពិនិត្យនេះ ជូនកម្មករ។

២- កម្មករនិយោជិតទាមទារ នៅពេលគ្មានការងារធ្វើសុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលពេញ និងសុំទូទាត់រំលើកឡើងវិញ។ ដោយឡែក ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនមិនឯកភាពតាមការទាមទារនោះបានឡើយ ដោយក្នុងករណីគ្មានការងារធ្វើ ក្រុមហ៊ុនអនុវត្តតាមការព្រមព្រៀងកន្លងមក។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្ដីអំពីការមិនសះជា លេខ ១១៦១ ក.ប/អ.ក/វ.ក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨។

## សវនាការ និង សន្ទេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្ដាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០នាទី ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ូភើចិច ស្ដីពីទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យកាន់តែល្អប្រសើរ។ បន្ទាប់មក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយជាបន្តបន្ទាប់ និងផ្សះផ្សាចុងក្រោយ នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៨ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០៨ ចំណុច។ ចំណុចមិនសះជាចំនួន ០២ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ តាមរបាយការណ៍ស្ដីពីវិវាទការងាររួមមិនសះជា លេខ ១១៦១ ក.ប/អ.ក/វ.ក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សា លើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ១៤:០០នាទីល្ងាច។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់អាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាចំណុចមិនសះជាទាំង ០២ ចំណុច បន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ជូនលោក ស សំណាង មេធាវីប្រចាំក្រុមហ៊ុន និងលោក លីវ ម៉ាន់ ប្រធានរដ្ឋបាលក្រុមហ៊ុន ដើម្បីដោះស្រាយវិវាទការងារ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ជំនួសនាយិកាក្រុមហ៊ុន ជាប់រវល់ភារកិច្ច ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៃក្រុមហ៊ុន ស៊ូភើចិច ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ ។

៣- បទបញ្ជាផ្ទៃក្នុងនៃក្រុមហ៊ុន ស៊ូភើចិច ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ ។

៤- លក្ខន្តិកៈនៃក្រុមហ៊ុន ស៊ូភើចិច ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៣។

៥- កិច្ចសន្យាសុំបំរើការងារ (គំរូ)

៦- លិខិតបំពេញប្រវត្តិរូបស្នើសុំការងារ (គំរូ)

៧- លក្ខខណ្ឌការងារ (គំរូ)

៨- កិច្ចព្រមព្រៀងបំរើការងារ (គំរូ)

៩- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខាំបូឌា ស្ពតវែរ អ៊ឹមអេហ្វប៊ី ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- បង្កាន់ដៃទទួលសំណុំរឿងរបស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពីសហព័ន្ធសហជីពយុវជនខ្មែរ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨។

២- ពាក្យបណ្តឹងរបស់កម្មករនិយោជិត គោរពជូន លោកប្រធានសហព័ន្ធ សហជីពយុវជនខ្មែរ ស្តីពីការសុំឱ្យលោកប្រធានមេត្តាជួយអន្តរាគមន៍ និងដោះស្រាយលក្ខខណ្ឌការងារមួយចំនួន (មានកម្មករនិយោជិតចំនួន ៤០នាក់ ផ្តិតស្នាមមេដៃ) ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៨។

៣- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូនលោកនាយកក្រុមហ៊ុន ស៊ូភើចិច ស្តីពីការជូនដំណឹងការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការ សហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន សូភើចិច លេខ ៥៩០ ស.ស.យ.ខ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៨។

៤- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការសុំឱ្យលោកប្រធានមេត្តាជួយដោះស្រាយនូវករណីវិវាទការងារក្នុងក្រុមហ៊ុន ស៊ូភើចិច ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

៥- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូនលោកនាយកក្រុមហ៊ុន ស៊ូភើថិច ស្តីពីសំណើសុំជួបពិភាក្សា និងសម្របសម្រួលនូវវិវាទការងាររបស់កម្មករនិយោជិតក្រុមហ៊ុន ស៊ូភើថិច ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ស៊ូភើថិច លេខ ១១៦១ ក.ប/អ.ក/វ.ក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួម ក្រុមហ៊ុន ស៊ូភើថិច ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៨។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦៧៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦៧៨ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ស៊ូភើថិច មានជួលកម្មករនិយោជិត សរុបចំនួនប្រមាណ ៤៧៧០ នាក់។
- សហជីពយុវជនខ្មែរនៃក្រុមហ៊ុន ជាភាគីដើមបណ្តឹងក្នុងសំណុំរឿងនេះ។ សហជីពយុវជនខ្មែរ បានបញ្ជាក់នៅក្នុងសវនាការថា សហជីពមិនទាន់មានវិញ្ញាបនប័ត្រចុះបញ្ជិកានៅឡើយទេ ដោយហេតុថា សហជីពទើបតែបានដាក់ពាក្យទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សុំចុះបញ្ជិកាសហជីព និងទទួលបានបង្កាន់ដៃសុំចុះបញ្ជិកា។ ប៉ុន្តែ ភាគីសហជីពមិនបានផ្តល់បង្កាន់ដៃសុំចុះបញ្ជិកាសហជីពនេះ ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន សងប្រាក់ថ្លៃពិនិត្យកាយសម្បទាកន្លងមក ជូនកម្មករនិយោជិតទាំងអស់វិញ តាមតម្លៃជាក់ស្តែងដែលកម្មករនិយោជិតបានចំណាយ**

- ភាគីកម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុន ចេញសងប្រាក់ថ្លៃពិនិត្យកាយសម្បទា ជូនកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ពីព្រោះកន្លងមក ចាប់តាំងពីបើកដំណើរការមក ក្រុមហ៊ុនមិនដែលចេញសងប្រាក់ថ្លៃពិនិត្យកាយសម្បទាជូនកម្មករនិយោជិតទេ។
- ក្រុមហ៊ុនបានបញ្ជាក់នៅក្នុងសវនាការថា ក្រុមហ៊ុនមិនអាចចេញថ្លៃពិនិត្យសុខភាពបានទេ ពីព្រោះការពិនិត្យសុខភាពដំបូងរបស់កម្មករនិយោជិត គឺជាលក្ខខណ្ឌ ដើម្បីបំពេញសំណុំបែបបទ របស់ក្រុមហ៊ុនមុននឹងយកកម្មករឱ្យចូលធ្វើការ បន្ទាប់ពីកម្មករនិយោជិតនោះធ្វើតេស្តជាប់ តាមការប្រកាសរបស់ក្រុមហ៊ុន ទោះបីសំបុត្រពេទ្យនោះ ដាក់ឈ្មោះពីក្រុមហ៊ុនណាក៏ដោយ ក៏ក្រុមហ៊ុនទទួលយកដែរ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់បន្ថែមថា ក្រុមហ៊ុនចេញថ្លៃពិនិត្យសុខភាព ជូនកម្មករនិយោជិត ក្នុងករណីដែលក្រុមហ៊ុនត្រូវបញ្ជូនកម្មករនិយោជិតទៅពិនិត្យសុខភាពជាកាលិក ក្រុមហ៊ុននឹងចេញថ្លៃពិនិត្យសុខភាពជូន។ ហេតុនេះហើយ ក្រុមហ៊ុនមិនអាចចេញសងថ្លៃពិនិត្យសុខភាព តាមការទាមទាររបស់កម្មករនិយោជិតបានទេ។ ប៉ុន្តែក្រុមហ៊ុនមិនធ្លាប់ដែលបានបញ្ជូនកម្មករនិយោជិតទៅពិនិត្យសុខភាពទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា កម្មករដែលបានទៅពិនិត្យសុខភាព លុះត្រាតែមានដាក់ឈ្មោះក្រុមហ៊ុន ដែលកម្មករនិយោជិតត្រូវចូលធ្វើការ ទើបពេទ្យចេញលិខិតបញ្ជាក់ការពិនិត្យសុខភាពជូនកម្មករនិយោជិតនោះ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមថា កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ចេញសងថ្លៃពិនិត្យសុខភាព គឺសម្រាប់កម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ។ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានបញ្ជាក់ថា តើកម្មករនិយោជិតទាំងអស់នោះ មានចំនួនប៉ុន្មាននាក់ទេ ដែលទាមទារឱ្យក្រុមហ៊ុនសងប្រាក់ថ្លៃពិនិត្យសុខភាព។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ជូនភាគីកម្មករនិយោជិតនៅក្នុងសវនាការថា តើសហជីព និងភាគីកម្មករនិយោជិតដឹងទេថា តើកម្មករនិយោជិតទាំងអស់ ដែលមានទាមទារឱ្យក្រុមហ៊ុនចេញសងថ្លៃពិនិត្យសុខភាពមានប៉ុន្មាននាក់? ភាគីកម្មករនិយោជិតឆ្លើយថា មិនដឹងថា មានចំនួនប៉ុន្មាននាក់ទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ជូនភាគីកម្មករនិយោជិតទៀតថា តើភាគីកម្មករអាចធ្វើបញ្ជីឈ្មោះកម្មករនិយោជិត (មានផ្តិតស្នាមមេដៃ ឬចុះហត្ថលេខា) ដែលទាមទារឱ្យក្រុមហ៊ុនចេញសងថ្លៃពិនិត្យសុខភាព និងឯកសារ ឬ ភស្តុតាងផ្សេង ដែលពាក់ព័ន្ធនឹងការទាមទារមកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដែរឬទេ? ភាគីកម្មករនិយោជិតឆ្លើយថា នឹងធ្វើបញ្ជីឈ្មោះកម្មករនិយោជិតដែលទាម

ទារនេះជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨។ ប៉ុន្តែរហូតដល់កាលបរិច្ឆេទកំណត់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ នេះ ភាគីកម្មករខកខានមិនបានផ្ញើបញ្ជីឈ្មោះកម្មករនិយោជិត ក៏ដូចជាឯកសារ ឬភស្តុតាង ដែលទាក់ទងនឹងការទាមទារខាងលើនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ទេ។

- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏បានឱ្យក្រុមហ៊ុន ផ្ដល់បញ្ជីកម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនសងថ្លៃពិនិត្យសុខភាពនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ។ ប៉ុន្តែក្រុមហ៊ុនមិនបានផ្ដល់ជូនមកទេ។

**ចំណុចវិវាទទី២ : <u>កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលពេញ និងសុំទូទាត់រំលឹកឡើងវិញ នៅពេលគ្មានការងារធ្វើកន្លងមក</u>**

- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន គិតប្រាក់ឈ្នួលពេញ និងទូទាត់រំលឹកឡើងវិញ ពីព្រោះកន្លងមក នៅពេលដែលក្រុមហ៊ុន គ្មានការងារឱ្យកម្មករនិយោជិតធ្វើ ក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួលចំនួនតែ ៥០ ភាគរយទេ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា កម្មករនិយោជិតមិនទាមទារឱ្យក្រុមហ៊ុនទូទាត់សងរំលឹកប្រាក់ឈ្នួលបន្ថែម ៥០ ភាគរយ ឡើងវិញ នៅពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើកន្លងមកទេ ដោយហេតុថា កម្មករនិយោជិតមិនបានចាំថា ថ្ងៃដែលគ្មានការងារធ្វើកន្លងមក នៅថ្ងៃ ខែ ឆ្នាំណាទេ។ ដូច្នេះ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួលពេញ នៅពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ គឺទាមទារសម្រាប់នៅថ្ងៃអនាគត។
- ភាគីនិយោជក និងភាគីកម្មករនិយោជិតបញ្ជាក់ថា ក្រុមហ៊ុនមិនបានអនុវត្តការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទេ ក្នុងកំឡុងពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើកន្លងមក។
- ភាគីនិយោជកបានបញ្ជាក់ថា កន្លងនៅពេលដែលក្រុមហ៊ុនដឹងថា ថ្ងៃណាដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ ក្រុមហ៊ុននឹងជូនដំណឹងដល់កម្មករនិយោជិតមួយថ្ងៃមុន ដោយក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួល ៥០ ភាគរយ។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនមិនដឹងមុន ថ្ងៃណាដែលគ្មានការងារធ្វើ ពីព្រោះវាអាស្រ័យលើអ្នកបញ្ជាទិញ ហើយកម្មករនិយោជិតបានមកដល់រោងចក្រនោះ បើក្រុមហ៊ុនចាត់ចែងឱ្យកម្មករនិយោជិត ត្រឡប់ទៅផ្ទះវិញ ក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួល ៥០ ភាគរយ បើក្រុមហ៊ុនចាត់ចែងរកការងារកន្លែងផ្សេង ដែលសមស្របតាមសមត្ថភាព និងជំនាញរបស់ពួកគាត់ ក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួល ១០០ ភាគរយ ហើយកម្មករនិយោជិតបានព្រមព្រៀងអនុវត្តរួចហើយ ប៉ុន្តែមិនមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរទេ។ ដូច្នេះ ក្រុមហ៊ុនមិនអាចផ្ដល់ជូន តាមការទាមទាររបស់កម្មករនិយោជិតបានទេ។

## ហេតុផលនៃសេចក្តីសម្រេច

សហជីពយុវជនខ្មែរបានបញ្ជាក់នៅក្នុងសវនាការថា សហជីពមិនទាន់មានវិញ្ញាបនប័ត្រចុះបញ្ជិកា នៅឡើយទេ ដោយហេតុថា សហជីពទើបតែបានដាក់ពាក្យទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សុំចុះបញ្ជិកាសហជីព និងទទួលបានបង្កាន់ដៃសុំចុះបញ្ជិកា។ ប៉ុន្តែ ភាគីសហជីព មិនបានផ្តល់បង្កាន់ដៃសុំចុះបញ្ជិកាសហជីពនេះជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើសហជីពដែលមានវត្តមាននៅក្នុងសវនាការ អាចតំណាងឱ្យកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ដើម្បីធ្វើការទាមទារទៅលើចំណុចវិវាទទាំងពីរនេះ ដែរ ឬទេ?

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារចែងថា *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនេះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារដើម្បីសុំចុះបញ្ជិកា។...*

*ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះថា បានចុះបញ្ជិការួចហើយ។..."*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា២៦៨ ខាងលើនេះ មានន័យថា អង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ស្តីពីការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈនោះ ទទួលបានការចុះបញ្ជិកា និងមានការទទួលស្គាល់ពីក្រសួងទទួលបន្ទុកវិស័យការងារ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដែរថា សិទ្ធិ និងផលប្រយោជន៍នេះ រួមបញ្ចូលទាំងសិទ្ធិរបស់សហជីពក្នុងការតំណាងសមាជិករបស់ខ្លួនមកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៦២/០៦-ហ្វ៊ីក ស៊ូ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ និងលេខ ៣១/០៨-សៅធនី ប៉េរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២*។)

ដូច្នេះ យោងតាមមាត្រា២៦៨ នៃច្បាប់ស្តីពីការងារខាងលើ សហជីពនេះមិនទាន់បានទទួលសិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់នៅឡើងទេ។ បានន័យថា សហជីពយុវជនខ្មែរមិនទាន់មានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីនាំយកវិវាទមកដោះស្រាយ តាងនាមឱ្យសមាជិករបស់ខ្លួន នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទេ។

ម្យ៉ាងវិញទៀត នៅក្នុងសេចក្តីបង្គាប់លេខ ១២៨/០៨-វេយ ហ៊ួ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *" សហជីពដែលមានវិញ្ញាបនប័ត្រចុះបញ្ជិកាត្រឹមត្រូវ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួចហើយ គឺភាគីសហជីពមានសិទ្ធិនាំយកវិវាទរបស់សមាជិកខ្លួន មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយពុំចាំបាច់មានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទេ។ ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណា ទៅលើការ*

*ទាមទារទេ ប្រសិនបើសហជីពដែលជាភាគីដើមបណ្តឹងពុំទាន់មានវិញ្ញាបនប័ត្រចុះបញ្ជិកានៅឡើយ ។*" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១២៨/០៨-វេយ ហ៊ូ ហេតុផលនៃសេចក្តីសម្រេច*) ។

ក្រុមប្រឹអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។ ដូច្នេះ ក្នុងករណីនេះ សហជីពយុវជនខ្មែរ ពុំទាន់មានសិទ្ធិតាមផ្លូវច្បាប់ ជាតំណាងឱ្យកម្មករនិយោជិត ដែលជាសមាជិករបស់ខ្លួននៅឡើយទេ ។

ទោះជាយ៉ាងណាក៏ដោយ ប្រការ១៩ នៃប្រកាស លេខ ០៩៩ កសបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល អនុញ្ញាតឱ្យបុគ្គល ដែលមិនមែនជាភាគីវិវាទ ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីវិវាទ មកធ្វើជាតំណាងក្នុងការដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាណ្តាលបាន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រការនេះ មានន័យថា ទោះជាសហជីពយុវជនខ្មែរ មិនទាន់មានវិញ្ញាបនប័ត្រ ចុះបញ្ជិកា ឬមិនទាន់បានដាក់ពាក្យសុំចុះបញ្ជិកាក៏ដោយ ក៏សហជីពនេះ អាចតំណាងឱ្យភាគីវិវាទមកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន ដរាបណាសហជីពនេះ បានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ពីកម្មករនិយោជិតដែលធ្វើការប្តឹងទាមទារ ។

ក្នុងសំណុំរឿងនេះភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា នឹងធ្វើបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨។ ហើយរហូតដល់កាលបរិច្ឆេទកំណត់ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ នេះ ភាគីកម្មករនិយោជិតខកខានមិនបានធ្វើបញ្ជីឈ្មោះកម្មករនិយោជិត ក៏ដូចជាឯកសារ ឬភស្តុតាង ដែលទាក់ទងនឹងការទាមទារខាងលើនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា កម្មករនិយោជិតបានធ្វើពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៨ គោរពជូនលោកប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីការសុំឱ្យលោកប្រធានមេត្តាជួយអន្តរាគមន៍ និងដោះស្រាយលក្ខខណ្ឌការងារមួយចំនួន (មានកម្មករនិយោជិតចំនួន ៤០នាក់ ផ្តិតស្នាមមេដៃ) ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណាចំណុចវិវាទទាំងពីរចំណុចនេះ សម្រាប់តែកម្មករនិយោជិតទាំង ៤០នាក់ ដែលជាដើមបណ្តឹងប៉ុណ្ណោះ ។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន សងប្រាក់ថ្លៃពិនិត្យកាយសម្បទា ជូនកម្មករនិយោជិតទាំងអស់វិញ តាមតម្លៃជាក់ស្តែងដែលកម្មករបានចំណាយកន្លងមក**

មាត្រា២៤៧ នៃច្បាប់ស្តីពីការងារ ចែងថា "*ក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវចេញប្រកាសកំណត់៖*

(ក) *លក្ខខណ្ឌដែលត្រូវពិនិត្យសុខភាពនៅពេលរើសបុគ្គលិកថ្មី និងជ្រើសរើសយកមកធ្វើការឡើងវិញ ពិនិត្យសុខភាពជាទៀ-កាលិក និងពិនិត្យសុខភាពជាពិសេស ។*

(គ) *លក្ខខណ្ឌដែលតម្រូវឱ្យនិយោជកចាត់ចែង និងរៀបចំដោយចេញសោហ៊ុយខ្លួនឯងគឺ:......៤-ការពិនិត្យសុខភាពនិយោជិតកម្មករ ដូចមានចែងក្នុងចំណុច ក នៃមាត្រានេះ ។"*

ប្រការ២ (ឃ)នៃប្រកាសអន្តរក្រសួង លេខ ១១៩១ សហវ.ប្រក.ចមព ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីអាករប័ណ្ណការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យសុខភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា " *ចំពោះតំលៃសេវាលើការពិនិត្យសុខភាព ដែលនិយោជកត្រូវបង់ ត្រូវបានកំណត់ដូចខាងក្រោម:.. ឃ - ចំពោះកម្មករនិយោជិតជនជាតិខ្មែរម្នាក់ៗ ត្រូវបានកំណត់ចំនួន ១២,០០០ (ដប់ពីរពាន់រៀល) ។* "

ផ្អែកលើខ្លឹមសារនៃមាត្រា២៤៧ (ក )និង (គ) នៃច្បាប់ស្តីពីការងារ និង ប្រការ ២ (ឃ)នៃប្រកាសអន្តរក្រសួង លេខ ១១៩១ សហវ.ប្រក.ចមព ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាករប័ណ្ណការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យសុខភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចចេញថ្លៃពិនិត្យសុខភាពទៅឱ្យកម្មករនិយោជិត ។

បន្ថែមពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា ក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យនិយោជកបង់ថ្លៃពិនិត្យសុខភាពដល់កម្មករនិយោជិត ដែលបានចេញប្រាក់ពិនិត្យសុខភាពដោយខ្លួនឯង។ (សូមមើលសំណុំរឿងលេខ *លេខ ២១/០៣-ឡាយ អិល កាំបូឌា ហេតុផលសេចក្តីសម្រេចចំណុចវិវាទទី៧ លេខ ១៩/០៤-ក្បាលកោះ២ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៥៣/០៤-គង់ហុង ៣ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទ៣ លេខ ៥៩/០៥-តាក ហ្វាត ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥ លេខ ០៥/០៦-ដាប់ប៊ិលយូ អ៊ែន៏ ឌី ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ លេខ ៥៦/០៧-ហ្គោល ដិន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ លេខ ៨៦/០៧- ថាហ្គិតស៊ូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ លេខ ៩៣/០៧-គ្លូបល ហ្វូតវែរ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទី២ លេខ ៩៨/០៧-ស្កាយស៊ីណូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ លេខ ៤០/០៨-ស៊ុប ព្រីម ហ្គាមេន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤ និងលេខ៥២/០៨-ស៊ុប ព្រីម ហ្គាមេន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ ) ។*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសេចក្តីបង្គាប់មុនៗដែរ គឺនិយោជកមានកាតព្វកិច្ចបង់ថ្លៃពិនិត្យសុខភាពឱ្យកម្មករនិយោជិតរបស់ខ្លួន។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចក្នុងការតម្រូវឱ្យភាគីនៃវិវាទផ្តល់នូវភស្តុតាង(សូមមើលប្រការ១៨ និង២៤ នៃប្រកាសលេខ ០៩៩/២០០៤) ។ មាត្រា២៥នៃប្រកាស០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា

*"ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវមានសេរីភាពក្នុងការកំណត់អំពីភាព ដែលអាចទទួលយកបាន ភាពពាក់ព័ន្ធ ភាពសំខាន់ និងទម្ងន់ភស្តុតាង និងមានសេរីភាពក្នុងការកំណត់ឱ្យភាគីណាមួយលើកភស្តុតាង មកបញ្ជាក់ទៀតផង "។*

ពាក់ព័ន្ធនឹងការទាមទារនេះ ភាគីកម្មករនិយោជិតមិនបានបញ្ជាក់នៅក្នុងសវនាការថា កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ចេញសងប្រាក់ថ្លៃពិនិត្យសុខភាពប៉ុន្មានទេ គឺកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនសងតាមតម្លៃជាក់ស្តែងដែលបានចំណាយ ហើយភាគីកម្មករនិយោជិតមិនបានបញ្ជាក់ដែរថា តើកម្មករនិយោជិតទាំងនោះបានចេញថ្លៃពិនិត្យកាយសម្បទា ដោយខ្លួនឯងអស់ថ្លៃប៉ុន្មាន និងទៅពិនិត្យកាយសម្បទានៅពេលណាទេ ដែលទាមទារឱ្យក្រុមហ៊ុនសងថ្លៃពិនិត្យសុខភាពនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបង្គាប់ឱ្យភាគីកម្មករនិយោជិត ផ្តល់ឯកសារ ភស្តុតាង និងបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទានេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ប៉ុន្តែភាគីកម្មករនិយោជិតខកខានមិនបានធ្វើបញ្ជីឈ្មោះកម្មករនិយោជិត ក៏ដូចជាឯកសារ ឬភស្តុតាង ដែលទាក់ទងនឹងការទាមទារខាងលើនេះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គិតចាប់ពីថ្ងៃសវនាការនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ មកដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ មានរយៈពេលមួយសប្តាហ៍ គឺគ្រប់គ្រាន់សម្រាប់ឱ្យភាគីកម្មករធ្វើបញ្ជីឈ្មោះកម្មករនិយោជិតដែលទាមទារឱ្យក្រុមហ៊ុនសងប្រាក់ថ្លៃពិនិត្យសុខភាពនេះ។

ជាទូទៅ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ក្នុងករណីគ្មានភស្តុតាងគ្រប់គ្រាន់ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៦៣/០៤-សាញ វីវេ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤ លេខ ៧៩/០៥-អេវើហ្គ្រីន ហេតុផលសម្រេចចំណុច វិវាទទី១ លេខ ៩៩/០៦-សៅធំបាយ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥ លេខ ៧៤/០៧-គួបល អាប៉ារ៉ែល ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៩១/០៧-ជេ ខេ ហេតុផល នៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៩៤/០៧- ហ្វូរធ្យូន ហ្គាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦ និង៨ លេខ ៤៤/០៨-ស៊ីវ គីញ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១និងទី៣ លេខ ១០១/០៨-ជីឌីអ៊ីម ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និងទី២ លេខ ១០៨/០៨-ហ៊ូ ហ្គោ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤ និងលេខ ១១៥/០៨-ថប វ័ន្ត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១*)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការសម្រេចរបស់ក្រុមអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។ ដូច្នេះ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនចេញសងប្រាក់ថ្លៃពិនិត្យសុខភាព ជូនកម្មករនិយោជិតវិញ តាមតម្លៃជាក់ស្តែងដែលកម្មករនិយោជិតបានចំណាយ កន្លងមក។

ARBITRATION COUNCIL

**ចំណុចវិវាទទី២ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលពេញ និងសុំទូទាត់រំលឹកឡើងវិញ នៅពេលគ្មានការងារធ្វើកន្លងមក**

ពាក់ព័ន្ធនឹងការទាមទារនេះ ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា កម្មករនិយោជិតមិនទាមទារឱ្យក្រុមហ៊ុនទូទាត់សងរំលឹកប្រាក់ឈ្នួលបន្ថែម ៥០ភាគរយ ឡើងវិញ នៅពេលដែលក្រុមហ៊ុន គ្មានការងារឱ្យកម្មករនិយោជិតធ្វើកន្លងមកទេ ដោយហេតុថា កម្មករនិយោជិតមិនបានចាំថា ថ្ងៃដែលគ្មានការងារធ្វើកន្លងមក នៅថ្ងៃ ខែ ឆ្នាំណាទេ។ ដូច្នេះ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពេញ នៅពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ នៅថ្ងៃអនាគត។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាដូចខាងក្រោមៈ

ជាគោលការណ៍ តាមច្បាប់ស្តីពីការងារ បានចែងអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ ហើយការព្យួរកិច្ចសន្យាការងារ ត្រូវធ្វើឡើងតាមនីតិវិធីនៃច្បាប់ស្តីពីការងារ ដូចមានចែងក្នុងមាត្រា ៧១ (១១) ដោយមូលហេតុដូចខាងក្រោម :

*"១-នៅពេលដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពី០២ខែ ។*

*២-ការព្យួរសកម្មភាពនេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ ។"*

ម្យ៉ាងទៀត មាត្រា ៧២ (១) នៃច្បាប់ស្តីពីការងារបានចែងថា :" *ការព្យួរកិច្ចសន្យាការងារ នាំអោយប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោល គឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការអោយនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលកំណត់អោយនិយោជកផ្តល់ប្រាក់ឈ្នួល អោយកម្មករនិយោជិត។..."*

តាមន័យនេះ ជាទូទៅ ទាក់ទងនឹងការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនត្រូវមានការជូនដំណឹង ទៅនាយកដ្ឋានអធិការកិច្ចការងារ និងមានការពិនិត្យ និងបញ្ជាក់ពីអធិការកិច្ចការងារជុំវិញបញ្ហាព្យួរកិច្ចសន្យាការងារនេះ។ មានន័យថា អធិការកិច្ចការងារមានភារកិច្ចចុះត្រួតពិនិត្យ និងផ្តល់យោបល់ជុំវិញសកម្មភាពព្យួរការងាររបស់ក្រុមហ៊ុនថា ពិតជាអនុលោមទៅតាមភាពជាក់ស្តែងនៃស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ចពិតប្រាកដមែន។ (សូមមើលសេចក្តីបង្គាប់លេខ *២៧/០៨-អាក ឃឹត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ច្បាប់ស្តីពីការងារ បានផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុន ក្នុងការព្យួរកិច្ចសន្យាការងារ ប៉ុន្តែការព្យួរកិច្ចសន្យាការងារនេះ និយោជកត្រូវធ្វើបែបបទជូនដំណឹង ទៅអធិការកិច្ចការងារអំពីមូលហេតុ ដែលបណ្តាលក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិត និងរយៈពេលនៃការព្យួរការងារនោះ។

ប្រសិនបើ ក្រុមហ៊ុនបានធ្វើបែបបទព្យួរការងារត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដោយការព្យួរការងារនោះ ត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យពីអធិការកិច្ចការងារនោះ ក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់

ឈ្នួលដល់កម្មករនិយោជិតឡើយ (សូមមើលមាត្រា ៧២ (១) នៃច្បាប់ស្តីពីការងារ)។ ប៉ុន្តែ ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ដល់កម្មករនិយោជិត ទោះបីជាពុំមានការងារឱ្យកម្មករធ្វើការក៏ដោយ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *២១/០៣-ឡូយ៉ាល់ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ៨ លេខ ០១/០៤-ញូវ ភាញ់ លេខ ៤៦/០៤-អេម អេន អេ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១ លេខ៦០/០៦-ញូវម៉េក្ស ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៧៤/០៧-គ្លូបលអាប៉ារ៉ែល ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ ២៧/០៨-អាក ឃិត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦ លេខ ២៨/០៨-បាញ្ញូ ជិស ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១និង២ និងលេខ ៥៣/០៨-យ៉ុង វ៉ា ទី១ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១*)។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក និង ភាគីកម្មករនិយោជិតបញ្ជាក់ថា កន្លងមកក្រុមហ៊ុនមិនបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទេ ក្នុងកំឡុងពេលដែលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ។ មានន័យថា ក្រុមហ៊ុនមិនបានធ្វើបែបបទជំរាបជូនទៅអធិការកិច្ចការងារទាក់ទងនឹងការព្យួរកិច្ចសន្យាការងារនេះឡើយ។ ផ្ទុយទៅវិញ ក្រុមហ៊ុនបានព្រមព្រៀងគ្នា ជាមួយកម្មករនិយោជិតនាពេលនោះថា នៅពេលក្រុមហ៊ុនពុំមានការងារឱ្យធ្វើ ក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ៥០ ភាគរយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងករណីនេះ ក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ ក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទេ។ ដូច្នេះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ដល់កម្មករនិយោជិត។

ប្រការ៣៤ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីអំពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា *"ក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារ និងប្រកាសនេះ ក្រុមអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសំរេចឱ្យភាគីវិវាទ ផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណងខូចខាតដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ បញ្ជាឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តទាំងឡាយណាដែលមិនស្របច្បាប់ ឬដែលត្រូវហាមឃាត់..."*

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចឱ្យក្រុមហ៊ុនបញ្ឈប់ជាបន្ទាន់ ការមិនអនុវត្តការព្យួរកិច្ចសន្យាការងារមិនបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ហើយត្រូវធានាថា ក្រុមហ៊ុនត្រូវអនុវត្តការព្យួរការងារ ឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីការងារ។

ចំពោះការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ១០០% នៅពេលក្រុមហ៊ុន គ្មានការងារឱ្យកម្មករនិយោជិតធ្វើ គឺទាមទារសម្រាប់ថ្ងៃអនាគត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំពោះបណ្តឹងសំរាប់វិវាទ ដែលមិនទាន់កើតឡើងបែបនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញ នូវអង្គហេតុ និង

ភស្តុតាង ជាក់លាក់ទាក់ទងនឹងកម្មករនិយោជិតដែលធ្វើការទាមទារ មកធ្វើការពិចារណា ដើម្បីសម្រេចបាន ឡើយ។

ទាក់ទងនឹងការទាមទារសម្រាប់ថ្ងៃអនាគត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបក ស្រាយថា *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្កើតឡើង ដើម្បីដោះស្រាយជម្លោះការងារ មិនមែនដើម្បីដោះស្រាយ បញ្ហាដែលមិនទាន់កើតឡើងនោះទេ។ "* *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០/០៣-ហ្សាក់ ស៊ីនតិក ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ ១៤/០៦- ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ ៤២/០៧- សោធន៍ បេ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣ ៥៨/០៧-៨ ស្តារ ស្ពត វែរ ហេតុផល នៃសេចក្តីសម្រេច ចំណុចវិវាទទី ១ លេខ១២២/០៧-យេន យូ អ៊ិន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤ លេខ ២៧/០៨- អាក ឃីត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦ និងលេខ៥៣/០៨-យុង វ៉ា ទី១ ហេតុផលនៃសេចក្តី សម្រេច ចំណុចវិវាទទី៤* )។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល ខាងលើដែរ ពីព្រោះគ្មានអ្នកណាអាចទាយទុកមុនពីហេតុការណ៍ដែលនឹងកើតមានឡើងនៅពេលអនាគតទេថា តើ បញ្ហានោះអាចនឹងកើតមាន ឬអត់ ហើយកើតនៅទីណា? នៅពេលណា? ហើយកម្មករនិយោជិតណាខ្លះដែលត្រូវ ប៉ះពាល់ ដូចជាឈ្មោះកម្មករនិយោជិតដែលធ្វើការទាមទារ កម្មករនិយោជិតនៅក្រុមណា? ផ្នែកណា? មានប៉ុន្មាន នាក់? ក្រុមហ៊ុនគ្មានការងារឱ្យធ្វើរយៈពេលប៉ុន្មានថ្ងៃ?។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៣៦/០៦- ម៉ុងដូតិច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥ លេខ៥៨/០៧-៨ ស្តារ ស្ពត វែរ ហេតុផលនៃសេចក្តី សម្រេច ចំណុចវិវាទទី១ និងលេខ ២៧/០៨-អាក ឃីត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦*)។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ ប្រាក់ឈ្នួលពេញ នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ សម្រាប់ថ្ងៃអនាគត។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សា អាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១**

- បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនចេញសងប្រាក់ថ្លៃពិនិត្យសុខភាព ជូនកម្មករ និយោជិតវិញ តាមតម្លៃជាក់ស្តែងដែលកម្មករបានចំណាយ កន្លងមក។

**ចំណុចវិវាទទី២**

-បង្គាប់ឱ្យក្រុមហ៊ុនបញ្ឈប់ជាបន្ទាន់ ការមិនអនុវត្តការព្យួរកិច្ចសន្យាការងារមិនបានត្រឹមត្រូវ តាមច្បាប់ស្តីពីការងារ ហើយត្រូវធានាថា ក្រុមហ៊ុនត្រូវអនុវត្តការព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីការងារ ។

-មិនពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពេញ នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ សម្រាប់ថ្ងៃអនាគត ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ឹុម សុន្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------

ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ១៣៦/០៨ ក្រុមហ៊ុន ស៊ូភើចិច

# យោបល់ជំទាស់ទៅនឹងចំណុចវិវាទទី១

- យោងតាមប្រកាស ៣៧ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ របស់ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខ្ញុំ **លីម សុវណ្ណា** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងចំណុចវិវាទទី ១ ត្រង់ហេតុផលនៃសេចក្តីសម្រេច នៃសេចក្តីបង្គាប់ លេខ ១៣៦/០៨-ក្រុមហ៊ុន ស៊ូភើចិច ដូចតទៅ :

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន សងប្រាក់ថ្លៃពិនិត្យកាយសម្បទា ជូនកម្មករនិយោជិតទាំងអស់វិញ តាមតម្លៃជាក់ស្តែងដែលកម្មករបានចំណាយកន្លងមក**

នៅក្នុងសវនាការ ភាគីនិយោជក និងភាគីកម្មករនិយោជិតបានទទួលស្គាល់ទាំងអស់គ្នាថា ក្រុមហ៊ុន ស៊ូភើចិច តែងតែដាក់ល័ក្ខខ័ណ្ឌឱ្យកម្មករនិយោជិតដែលសំភាសន៏ការងារជាប់ហើយ ត្រូវបំពេញបែបបទផ្សេងៗ ក្នុងនោះ មានល័ក្ខខ័ណ្ឌមួយ គឺតម្រូវឱ្យកម្មករនិយោជិតភ្ជាប់មកជាមួយនូវសំបុត្រពិនិត្យសុខភាពភ្ជាប់មកជាមួយ ។ បើគ្មានសំបុត្រពិនិត្យសុខភាពទេ ក្រុមហ៊ុនមិនចុះកិច្ចសន្យាការងារជាមួយទេ ហើយក្រុមហ៊ុនមិនចេញប្រាក់ថ្លៃពិនិត្យសុខភាពឡើយ ។ និយោជកអះអាងថា ការពិនិត្យសុខភាពនេះ គឺជាល័ក្ខខ័ណ្ឌមួយរបស់ក្រុមហ៊ុន មុននឹងចុះកិច្ចសន្យាការងារ បើក្រុមហ៊ុនឱ្យទៅពិនិត្យទើបក្រុមហ៊ុនចេញប្រាក់ ។ តែភាគីកម្មករនិយោជិតបានអះអាងថា បើគ្មានលិខិតបញ្ជាក់ធ្វើការនៅក្រុមហ៊ុនណាទេ ពេទ្យការងារនឹងមិនពិនិត្យសុខភាពឱ្យឡើយ ។ ដូចនេះយើងអាចកំណត់បានថា កម្មករនិយោជិតដែលចូលធ្វើការនៅក្នុងក្រុមហ៊ុន ស៊ូភើចិច សុទ្ធតែត្រូវបានពិនិត្យសុខភាព ដោយត្រូវបង់ប្រាក់របស់កម្មករនិយោជិតជាសាម៉ីខ្លួន ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំណុចនេះ ដូចខាងក្រោមៈ

មាត្រា ២៤៧ នៃច្បាប់ស្តីពីការងារ ចែងថា *"ក្រសួងទទួលបន្ទុកវិស័យការងារ ត្រូវចេញប្រកាសកំណត់:*

(ក) *លក្ខខណ្ឌដែលត្រូវពិនិត្យសុខភាពនៅពេលរើសបុគ្គលិកថ្មី និងជ្រើសរើសយកមកធ្វើការឡើងវិញ ពិនិត្យសុខភាពជាតាវកាលិក និងពិនិត្យសុខភាពជាពិសេស ។*

(គ) *លក្ខខណ្ឌដែលតម្រូវឱ្យនិយោជកចាត់ចែង និងរៀបចំដោយចេញសោហ៊ុយខ្លួនឯងគឺ:......៤-ការពិនិត្យសុខភាពកម្មករនិយោជិត ដូចមានចែងក្នុងចំណុច ក នៃមាត្រានេះ ។"*

ប្រការ ២ (ឃ) នៃប្រកាសអន្តរក្រសួង លេខ ១១៩១ សហវ.ប្រក.ចមព ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាករប័ណ្ណការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យសុខភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា *" ចំពោះតំលៃសេវាលើការពិនិត្យសុខភាព ដែលនិយោជកត្រូវបង់ ត្រូវបានកំណត់ដូចខាងក្រោម:.. ឃ - ចំពោះកម្មករនិយោជិតជនជាតិខ្មែរម្នាក់ៗ ត្រូវបានកំណត់ ចំនួន ១២,០០០ (ដប់ពីរពាន់រៀល) ។ "*

ផ្អែកលើខ្លឹមសារនៃមាត្រា ២៤៧ (ក) និង (គ) នៃច្បាប់ស្តីពីការងារ និង ប្រការ ២ (ឃ) នៃប្រកាសអន្តរក្រសួង លេខ ១១៩១ សហវ.ប្រក.ចមព ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាករប័ណ្ណការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យ /

សុខភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចចេញថ្លៃពិនិត្យសុខភាពទៅឱ្យកម្មករនិយោជិត ។ ចំពោះការដោះសារថា ការពិនិត្យសុខភាពមុនចុះកិច្ចសន្យាការងារ ជាល័ក្ខខ័ណ្ឌមួយដែលក្រុមហ៊ុនបានប្រកាសប្រាប់កម្មករនិយោជិតជាមុននោះ គឺមិនអាចឱ្យនិយោជករួចផុតពីការទទួលខុសត្រូវបានឡើយ ។

បន្ថែមពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា ក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបង្គាប់ឱ្យនិយោជកបង់ថ្លៃពិនិត្យសុខភាពដល់កម្មករនិយោជិត ដែលបានចេញប្រាក់ពិនិត្យសុខភាព ដោយខ្លួនឯង។ (សូមមើលសំណុំរឿងលេខ *លេខ ២១/០៣-ឡាយ អិល កាំបូឌា ហេតុផលសេចក្តីសម្រេច ចំណុចវិវាទទី ៧, លេខ ១៩/០៤-ក្បាលកោះ២ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ២, លេខ ៥៣/០៤-គង់ ហុង ៣ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទ ៣, លេខ ៥៩/០៥-តាក ហ្វាត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៥, លេខ ០៥/០៦-ដាប់ប៊ីលយូ អ៊ែន៍ ឌី ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១ លេខ ៥៦/០៧-ហ្គោល ដិន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២, លេខ ៨៦/០៧- ថាហ្គឹតស៊ូ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២, លេខ ៩៣/០៧- គួបល ហ្វតវែរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៩៨/០៧-ស្កាយស៊ីណូ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ លេខ ៤០/០៨-ស៊ុប ព្រីម ហ្គាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៤ និងលេខ៥២/០៨-ស៊ុប ព្រីម ហ្គាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុច វិវាទទី១* ) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសេចក្តីបង្គាប់មុនៗ ដែរ គឺនិយោជកមានកាតព្វកិច្ចបង់ថ្លៃពិនិត្យសុខភាពឱ្យកម្មករនិយោជិតរបស់ខ្លួន។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៣៦/០៨-ស៊ូភើតិច នេះ ខ្ញុំយល់ស្របនឹងការបកស្រាយថា សហជីពយុវជនខ្មែរ មិនមានសិទ្ធិតំណាងឱ្យកម្មករនិយោជិតនោះទេ ហេតុនេះការសម្រេចទាក់ទងនឹងសំណុំរឿងនេះ គឺទាក់ទងតែនឹងកម្មករ ៤០ នាក់ ដែលមានស្នាមមេដៃផ្ទេរសិទ្ធិ ហើយជាដើមបណ្តឹងប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំ សូមធ្វើការជំទាស់ទៅនឹងការសម្រេច ដែលបដិសេធការទាមទាររបស់កម្មករនិយោជិត ដោយខ្ញុំសូមធ្វើការពន្យល់នឹងសម្រេចផ្សេងដូចខាងក្រោម :

មាត្រា ១២០ នៃច្បាប់ស្តីពីការងារចែងថា : *"សិទ្ធិប្តឹងសុំបើកប្រាក់ឈ្នួលត្រូវផុតរលត់ក្នុងរយៈពេលបីឆ្នាំ ក្រោយពីថ្ងៃកំណត់បើកប្រាក់ឈ្នួល ។*

*គណទេយ្យ*[1] *ដែលស្ថិតនៅក្រោមការផុតរលត់សិទ្ធិនេះមាន: ប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់បន្ទាប់បន្សំនៃប្រាក់ឈ្នួល និងគណទេយ្យទាំងអស់របស់កម្មករ ដែលមានប្រភពចេញពីកិច្ចសន្យាការងារ ព្រមទាំងប្រាក់បំណាច់ ដែលត្រូវបាន ក្នុងករណីដេញចោលផង ។"*

តាមន័យនេះ ខ្ញុំយល់ឃើញថា បណ្តឹងទាមទារចំនួនទឹកប្រាក់ពិនិត្យសុខភាពនេះ គឺកើតចេញពីកិច្ចសន្យាការងារ ព្រោះថា វាជាលក្ខខណ្ឌមួយនៃកិច្ចសន្យាការងារ គឺកម្មករនិយោជិតត្រូវតែមានលិខិតពិនិត្យសុខភាព ដោយខ្លួនឯង ដោយអាជ្ញាយុកាល ✓

[1] គណទេយ្យ គឺមានន័យថា បណ្តឹងទាមទារសំណង ឬប្រាក់បំណុលដែលជំពាក់

នៃការទាមទារបណ្តឹងនេះមានរយៈពេលត្រឹមតែ ០៣ឆ្នាំ ប៉ុណ្ណោះ។ ដូចនេះ អាជ្ញាយុកាលនៃបណ្តឹងទាមទារប្រាក់ថ្លៃពិនិត្យសុខភាពក្នុងសំណុំរឿងនេះ គឺមានរយៈពេល ០៣ ឆ្នាំ ។

ប៉ុន្តែតើអាជ្ញាយុកាលនោះត្រូវចាប់ផ្តើមពីពេលណាមក? ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿង ៦១/០៧-អ៊ឹម និង វ៉ៅ ៣ បានបកស្រាយថា ដោយផ្អែកលើខ្លឹមសារនៃមាត្រា ១២០ នៃច្បាប់ស្តីពីការងារ អាជ្ញាយុកាល[២] នៃបណ្តឹងទាមទារសុំបើកប្រាក់ឈ្នួលរួមបញ្ចូលទាំងបណ្តឹងទាមទារប្រាក់ថ្លៃពិនិត្យសុខភាពផងនោះ មានរយៈពេល០៣ឆ្នាំ គិតចាប់ពីថ្ងៃ ដែលកម្មករនិយោជិតត្រូវទទួលបានអត្ថប្រយោជន៍នោះ ដោយអាចជាកាលបរិច្ឆេទចុះកិច្ចសន្យាការងារ ឬ ថ្ងៃទីមួយ ដែលកម្មករនិយោជិតចាប់ផ្តើមធ្វើការ ឬថ្ងៃ ដែលកម្មករនិយោជិតត្រូវទទួលបានប្រាក់ឈ្នួលជាដើម ។

ក្នុងករណីនេះ ខ្ញុំក៏ឯកភាពលើការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ គឺ អាជ្ញាយុកាលនៃបណ្តឹងទាមទារប្រាក់ថ្លៃពិនិត្យសុខភាពគឺមានចំនួន០៣ឆ្នាំ គិតចាប់ពីថ្ងៃដែលនិយោជកមានកាតព្វកិច្ចសងប្រាក់នេះត្រឡប់ទៅកម្មករនិយោជិតវិញ ។ ដោយសារក្រុមហ៊ុន ស៊ូភើថិច បានតម្រូវឱ្យកម្មករនិយោជិតដាក់សំបុត្រពេទ្យភ្ជាប់មកជាមួយមុនចុះកិច្ចសន្យាការងារ និយោជកអាចដឹង និងមានកាតព្វកិច្ចសងប្រាក់នេះទៅឱ្យកម្មករនិយោជិតនៅក្នុងថ្ងៃចុះកិច្ចសន្យាការងារនោះដែរ ។ ដូច្នេះអាជ្ញាយុកាលក៏ត្រូវគិតចាប់ពីថ្ងៃចុះកិច្ចសន្យាការងារ មានន័យថា អាជ្ញាយុកាលដែលមានរយៈពេល ០៣ ឆ្នាំនេះ ត្រូវគិតថយក្រោយ ០៣ ឆ្នាំ ដោយរាប់ចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០០៨ ដែលជាថ្ងៃកម្មករនិយោជិតដាក់ពាក្យបណ្តឹងទាមទារ (នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ឱ្យក្រុមហ៊ុនសងប្រាក់ពិនិត្យសុខភាពនេះវិញ ។

ដូច្នេះ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលគប្បីសម្រេចឱ្យនិយោជកសងថ្លៃពិនិត្យសុខភាព ដល់កម្មករនិយោជិតក្នុងចំណោមកម្មករនិយោជិតជាដើមបណ្តឹងចំនួន ៤០ នាក់ ដែលបានចុះកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ រហូតមកដល់ពេលដាក់បណ្តឹង នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨។ ៸៸

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

**លីម សុវណ្ណា**

---

[2] អាជ្ញាយុកាលនៃបណ្តឹង គឺជារយៈពេលដែលភាគីមានសិទ្ធិស្របច្បាប់ ក្នុងការទាមទារអ្វីមួយ ។